Association of the Blind in Cambodia

eifl
KNOWLEDGE WITHOUT BOUNDARIES

World Blind Union

UNDP
*Empowered lives.*
*Resilient nations.*

# ឯកសារសង្ខេប

សីហា ២០១៧

# សន្ធិសញ្ញាម៉ារ៉ាកេសស្តីពីជនពិការដែលពិបាកអានឯកសារបោះពុម្ព នៅកម្ពុជា

## សារសំខាន់ៗ

- ពិការភាពដែលនាំឲ្យពិបាកអាន អាចបង្កឡើងដោយសារពិការភាពផ្នែកគំហើញ ដូចជា ពិការភ្នែក ឬកម្សោយគំហើញ, ពិការភាពជុំវិញការអភិវឌ្ឍ/ការរៀនសូត្រ ដូចជា វិកលទស្សន៍ (dyslexia) និងអូទីសឹម, ឬពិការកាយសម្បទា ដូចជា ជំងឺផាគីនសុន និងពិការខ្វិនអវៈយវៈ ជាដើម។
- សន្ធិសញ្ញាម៉ារ៉ាកេសស្តីពីជនពិការដែលពិបាកអានឯកសារបោះពុម្ព (ហៅកាត់ថា "សន្ធិសញ្ញាម៉ារ៉ាកេស" ឬ "សន្ធិសញ្ញា") ផ្តល់នូវលទ្ធភាពឲ្យមានការបង្កើត ចែកចាយ និងផ្លោះប្តូរឆ្លងដែនរវាងប្រទេសមួយ និងប្រទេសមួយទៀត នូវឯកសារក្នុងទម្រង់ងាយស្រួលយល់ សម្រាប់ជនពិការដែលពិបាកអានឯកសារបោះពុម្ព។ វាអាចរួមចំណែកយ៉ាងធំធេងចំពោះការលើកកម្ពស់សេចក្តីថ្លៃថ្នូរ សិទ្ធិ និងសុខុមាលភាពរបស់ជនពិការដែលពិបាកអានឯកសារបោះពុម្ព និងការសម្រេចការអភិវឌ្ឍប្រកបដោយចីរភាព បរិយាប័ន្ន និងយុត្តិធម៌ នៅកម្ពុជា។
- ការខ្វះឯកសារបោះពុម្ពក្នុងទម្រង់ដែលងាយស្រួលយល់សម្រាប់ជនពិការទាំងនេះ មានន័យស្មើនឹងការមិនផ្តល់សិទ្ធិទទួលបានចំណេះដឹង ដែលជាសិទ្ធិមនុស្សជាមូលដ្ឋាន ដល់ជនពិការទាំងនោះ ដែលនាំឲ្យមានផលវិបាកធ្ងន់ធ្ងរដល់ការអភិវឌ្ឍរបស់ពួកគេ។ បញ្ហានេះរារាំងជនពិការដែលពិបាកអានឯកសារបោះពុម្ពមិនឲ្យអាចសម្រេចបាននូវសក្តានុពលពេញលេញរបស់ពួកគេក្នុងនាមជាមនុស្សដូចគេដូចឯង និងមិនឲ្យពួកគេអាចចូលរួមប្រកបដោយប្រសិទ្ធភាព ក្នុងការអប់រំ ទីផ្សារការងារ និងសកម្មភាពវប្បធម៌បាន។ បញ្ហានេះអាចនាំឲ្យជនពិការទាំងនេះបាត់បង់ឱកាស ធ្លាក់ចូលទៅក្នុងភាពក្រីក្រ និងស្ថិតក្នុងភាពឯកាមិនអាចចូលប្រឡូកក្នុងសកម្មភាពវប្បធម៌នានាបាន។
- ប្រទេសកម្ពុជា ជាប្រទេសមួយ ក្នុងចំណោមសមាជិកអាស៊ានតែពីរប្រទេសប៉ុណ្ណោះ ដែលបានចុះហត្ថលេខាលើសន្ធិសញ្ញាម៉ារ៉ាកេសនេះ ប៉ុន្តែមិនទាន់បានផ្តល់សច្ចាប័ន ដែលជាលក្ខខណ្ឌតម្រូវដើម្បីអាចចូលរួមក្នុងសន្ធិសញ្ញានេះ នៅឡើយ។
- សន្ធិសញ្ញាម៉ារ៉ាកេសនេះ មានភាពពាក់ព័ន្ធ និងមានសារៈសំខាន់ជាពិសេស សម្រាប់ប្រទេសកម្ពុជា ដោយសារតែជនពិការភ្នែក និងជនខ្សោយគំហើញ មានភាគរយខ្ពស់ ក្នុងចំណោមជនពិការសរុបក្នុងប្រទេសកម្ពុជា ពោលគឺរហូតដល់ ៣៥ ភាគរយ។
- ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធបច្ចុប្បន្នរបស់ប្រទេសកម្ពុជា មានបញ្ញត្តិដែលអនុញ្ញាតឲ្យមានការដាក់កំហិត និងករណីលើកលែង ដើម្បីផ្តល់ប្រយោជន៍ដល់ជនពិការ។ ប៉ុន្តែ វិសាលភាពនៃបញ្ញត្តិទាំងនេះចាំបាច់ត្រូវពង្រីកបន្ថែមទៀត ទើបអាចអនុលោមតាមសន្ធិសញ្ញាម៉ារ៉ាកេស និងអាចទាញប្រយោជន៍ពេញលេញពីសន្ធិសញ្ញានេះបាន។

- សន្ធិសញ្ញាម៉ារ៉ាកេសអាចបំពេញនាទីជាលិខិតុបករណ៍ច្បាប់ដ៏មានប្រសិទ្ធភាពមួយ សម្រាប់ពន្លឿនការអនុវត្តអនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិជនពិការ ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នកាលពីឆ្នាំ ២០១២។

## សាវតារ

ពិការភាពដែលនាំឲ្យពិបាកអានឯកសារបោះពុម្ព អាចបង្កឡើងដោយសារពិការភាពពាក់ព័ន្ធនឹងគំហើញ ដូចជាពិការភ្នែក និងកម្សោយគំហើញ, ពិការភាពជុំវិញការអភិវឌ្ឍ និងការរៀនសូត្រ ដូចជា វិកលទស្សន៍ ( dyslexia ) និងអូទីសឹម, ពិការភាពកាយសម្បទា ដូចជា ជំងឺផាគីនសុន និងពិការខ្វិនអវៈយវៈ ជាដើម។ ជនពិការដែលពិបាកអានឯកសារបោះពុម្ព ពុំអាចទទួលបានព័ត៌មានប្រកបដោយប្រសិទ្ធភាពពីឯកសារដែលគេបោះពុម្ពតាមបែបធម្មតា ( ដូចជា ដោយសារតែពួកគេមិនអាចមើលឃើញ/អានអត្ថបទ កាន់សៀវភៅ ឬបើកទំព័រសៀវភៅបាន ) បានឡើយ ដែលមានន័យថា ពួកគេត្រូវការឯកសារក្នុងទម្រង់ដែលផ្តល់ភាពងាយស្រួលដល់ពួកគេដូចជា ឯកសារប្រើប្រាស់អក្សរស្ទាប សម្លេង សៀវភៅអេឡិចត្រូនិច ឬឯកសារដែលប្រើពុម្ពអក្សរធំៗ។

ការកង្វះភាពទទួលបាននូវឯកសារក្នុងទម្រង់ដែលផ្តល់ភាពងាយស្រួលដល់ជនពិការ ដែលមានតំលៃមួយសមរម្យ និងទាន់ពេលវេលា បង្ករអោយមានការរាំងជនពិការដែលពិបាកអានឯកសារបោះពុម្ពរាប់លាននាក់នៅទូទាំងពិភពលោក មិនឲ្យទទួលបានប្រយោជន៍ពឱកាសអភិវឌ្ឍន៍សំខាន់ៗជាច្រើនសម្រាប់មនុស្ស។

មានការប៉ាន់ប្រមាណថា ក្នុងប្រទេសកំពុងអភិវឌ្ឍ មានសៀវភៅបោះពុម្ពតិចជាង ១% ហើយក្នុងប្រទេសអភិវឌ្ឍមានសៀវភៅបោះពុម្ពតិចជាង ៧% ដែលផលិតឡើង ក្នុងទម្រង់ងាយស្រួលយល់ សម្រាប់ជនពិការដែលពិបាកអានឯកសារបោះពុម្ព។[១] ពេលខ្លះ គេហៅស្ថានភាពនេះថា “ទុរភិក្សសៀវភៅ (book famine)”។ ការកើតមានជាទូទៅនូវបញ្ហាទុរភិក្សសៀវភៅបែបនេះ អាចធ្វើឲ្យជនពិការដែលពិបាកអានឯកសារបោះពុម្ព ត្រូវបានផាត់ចេញពីការអប់រំ ការងារ/មុខរបរ ការថែទាំសុខភាព សកម្មភាពវប្បធម៌ ឬធ្វើឲ្យពួកគេមិនអាចចូលរួមក្នុងរាល់ទិដ្ឋភាពទាំងអស់នៃជីវភាពនយោបាយ សេដ្ឋកិច្ច និងសង្គម។

មានការព្យាករថា ចំនួនមនុស្សដែលមានពិការភាពធ្វើឲ្យពិបាកអានឯកសារបោះពុម្ពនៅកម្ពុជា និងនៅទីកន្លែងដ៏ទៃទៀត នឹងមានការកើនឡើងក្នុងចំនួនកាន់តែច្រើន ដោយសារតែប្រជាជនកាន់តែមានវ័យជរា និងដោយសារតែការកើនឡើងនូវករណីជំងឺមិនឆ្លង ដូចជា ស្រ្ទូក (ដែលបណ្តាលអោយមានពិការភាព) និងទឹកនោមផ្អែមជាដើម (ដែលបណ្តាលអោយងងិតភ្នែក និងខូចខាតគំហើញ)។ ដូច្នេះការបង្កើនលទ្ធភាពទទួលបានឯកសារបោះពុម្ពក្នុងទម្រង់ងាយស្រួលអានសម្រាប់ជនពិការ រឹតតែមានសារៈសំខាន់ទៅទៀត នៅក្នុងសង្គមទូទៅ។

## សន្ធិសញ្ញាម៉ារ៉ាកេស

កត្តាមួយ ក្នុងចំណោមកត្តានានា ដែលរួមចំណែកនាំឲ្យមានបញ្ហា “ទុរភិក្សសៀវភៅ” កើតឡើង រួមមាន របាំងផ្នែកច្បាប់ ដែលរាំងដល់ការបង្កើត និងចែកចាយឯកសារបោះពុម្ព ក្នុងទម្រង់ផ្តល់ភាពងាយស្រួលដល់ជនពិការ និងការផ្តោះប្តូរឯកសារទាំងនេះឆ្លងព្រំប្រទល់ដែនរវាងប្រទេសមួយ និងប្រទេសមួយទៀត។ ឧទាហរណ៍ គេមិនអាចយកសៀវភៅពេញនិយមមួយក្បាល ដែលបោះពុម្ពក្នុងទម្រង់ងាយស្រួលយល់សម្រាប់ជនពិការក្នុងប្រទេស ក ទៅឲ្យជនពិការដែលពិបាកអានឯកសារបោះពុម្ព អង្គការជនពិការភ្នែក ឬបណ្ណាល័យក្នុងប្រទេស ខ បានឡើយ ដោយសារតែ បច្ចុប្បន្ននេះ ពុំមានក្របខ័ណ្ឌច្បាប់អន្តរជាតិ ដែលអនុញ្ញាតឲ្យមានការផ្តោះប្តូរសៀវភៅរវាងប្រទេសទាំងពីរបាន។ ដូច្នេះ ចាំបាច់ត្រូវតែមានការបង្កើតសៀវភៅក្នុងទម្រង់ងាយស្រួលយល់សម្រាប់ជនពិការដដែលនេះឡើងវិញក្នុងប្រទេស ខ ដែលធ្វើឲ្យមានការធ្វើការងារ និងការចំណាយធនធានត្រួតគ្នា ដើម្បីផលិតសៀវភៅដដែលនេះ។ ការកើនឡើងនូវចំណាយសម្រាប់ផលិតឯកសារដែលងាយស្រួលយល់សម្រាប់ជនពិកា រធ្វើឲ្យមានផលប៉ះពាល់ដល់ចំនួនសៀវភៅដែលអាចរកបានសម្រាប់ជនពិការ។

សន្ធិសញ្ញាម៉ារ៉ាកេសស្តីពីការបង្កភាពងាយស្រួលឲ្យជនពិការភ្នែក អ្នកខ្សោយគំហើញ ឬជនពិការដែលជួបការលំបាកក្នុងការអាន អាចអានឯកសារបោះពុម្ពបាន (ហៅកាត់ថា“សន្ធិសញ្ញាម៉ារ៉ាកេស” ឬ “សន្ធិសញ្ញា”) ដែលត្រូវបានរៀបចំចប់រួចរាល់ កាលពីខែ មិថុនា ឆ្នាំ ២០១៣ មានគោលបំណងដកចេញនូវរបាំងច្បាប់ទាំងនេះ។[២] សន្ធិសញ្ញានេះអាចត្រួសត្រាយផ្លូវឲ្យមានការបង្កើតនូវបរិយាកាសគតិយុត្តិដែលអំណោយផលដើម្បីបញ្ចប់បញ្ហា “ទុរភិក្សសៀវភៅ” ហើយក្នុងពេលជាមួយគ្នា ធានាឲ្យមានការការពារសិទ្ធិ និងផលប្រយោជន៍របស់អ្នកនិពន្ធ។

សន្ធិសញ្ញានេះ អាចដោះស្រាយស្ថានការណ៍នេះតាមរយៈការអនុញ្ញាតអោយមាន “អង្គភាពដែលទទួលបានការអនុញ្ញាត“ ដូចជាស្ថាប័នអង្គការជនពិការភ្នែក និងបណ្ណាល័យ ដើម្បីរួមគ្នាប្រមូលនូវភាពទទួលបានដូច្នេះកាត់បន្ថយការងារស្ទួន និងសន្សំសំចៃថវិការ ទៅលើករណីសាធារណៈជាច្រើន មូនិធិ និងជំនួយ និងបង្កើនចំនួនការរកបាននូវសៀវភៅងាយស្រួលអានសំរាប់ជនពិការ។

១ សម្ព័ន្ធជនពិការភ្នែកពិភពលោក (២០១៣) សេចក្តីប្រកាសព័ត៌មានស្តីពីការចរចាសន្ធិសញ្ញាសម្រាប់ជនពិការភ្នែកជាមួយនឹងអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ( WIPO ) អាចរកបានតាមរយៈគេហទំព័រ http://www.worldblindunion.org/english/news/pages/press-release-wipo-negotiations-treaty-for-blind-people.aspx

២ សូមមើលគេហទំព័រនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) សម្រាប់ព័ត៌មានលំអិត http://www.wipo.int/treaties/en/ip/marrakesh/

បណ្ណាល័យគឺជាគន្លឹះជោគជ័យនៃសន្ធិសញ្ញា ពីព្រោះនៅទូទាំងពិភពលោកបណ្ណាល័យគឺជាទីតាំងចម្បងមួយនៃអក្សរស្ទាប សំលេង ឯកសារដែលប្រើពុម្ពអក្សរធំៗ និងសំភារៈដែលមានទម្រង់ជាអេឡិចត្រូនិកសំរាប់ជនពិការភ្នែក និងអ្នកខ្វះខាតគំហើញ។ លើសពីនេះទៅទៀតនៅក្នុងសន្ធិសញ្ញានេះ មានតែស្ថាប័នអង្គការជនពិការភ្នែក បណ្ណាល័យ និង "អង្គភាពដែលទទួលបានការអនុញ្ញាត" ប៉ុណ្ណោះមានសិទ្ធិស្របច្បាប់ក្នុងការចែកចាយឯកសារក្នុងទម្រង់ងាយស្រួលសំរាប់ជនពិការទៅប្រទេសដ៏ទៃផ្សេងៗទៀត។

ទិដ្ឋភាពសំខាន់បំផុតនៃ សន្ធិសញ្ញាម៉ារ៉ាកេស គឺថាវិសាលភាពរបស់វាមិនមែនគ្របដណ្តប់តែជនពិការភ្នែក និងអ្នកខ្វះខាតគំហើញប៉ុណ្ណោះទេ ប៉ុន្តែវាបានគ្របដណ្តប់ទៅដល់ជនពិការដែលពិបាកអានឯកសារបោះពុម្ពដ៏ទៃផ្សេងទៀត ដែលត្រូវបានព្យាករណ៍ថានឹងមានការកើនឡើងដោយសារតែប្រជាជនកាន់តែមានវ័យជរា និងដោយសារតែការកើនឡើងនូវករណីជំងឺមិនឆ្លងដូចបានរៀបរាប់ខាងលើ។

សន្ធិសញ្ញាម៉ារ៉ាកេស គឺជាសន្ធិសញ្ញាសិទ្ធអ្នកនិពន្ធដំបូងដែលតំកល់គោលការណ៍សិទ្ធិមនុស្សជាចម្បងមានការផ្សារភ្ជាប់ជាក់លាក់ទៅនឹងសេចក្តីថ្លែងការជាសាកលស្តីពីសិទ្ធិមនុស្ស និងអនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិជនពិការ ( UNCRPD )។

ការបន្តកើតឡើងនូវបញ្ហា "ទុរភិក្សសៀវភៅ" គឺជានិន្នាការផ្ទុយនឹងស្មារតីនៃអនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិជនពិការ ( UNCRPD ) និងកាតព្វកិច្ចកើតចេញពីអនុសញ្ញានេះ ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នកាលពីឆ្នាំ ២០១២។ ជាពិសេស សន្ធិសញ្ញាម៉ារ៉ាកេសនឹងជួយឲ្យប្រទេសកម្ពុជាអាចបំពេញតាមកាតព្វកិច្ចដែលត្រូវបានចែងជាក់លាក់ក្នុងអនុសញ្ញា UNCRPD ដូចជា មាត្រា ៩ ស្តីពីសិទ្ធិទទួលបានព័ត៌មាន មាត្រា ៣០ ( ១ ) ( ក ) ស្តីពីការចូលរួមក្នុងសកម្មភាពវប្បធម៌ តាមរយៈការទទួលបានសម្ភារ/ឯកសារវប្បធម៌ក្នុងទម្រង់ងាយស្រួលយល់សម្រាប់ជនពិការ និងមាត្រា ៣០ ( ៣ ) ស្តីពីការធានាថា "ច្បាប់ការពារកម្មសិទ្ធិបញ្ញានឹងមិនបង្កឲ្យមានរបាំងមិនសមហេតុសមផល ឬរបាំងដែលមានចរិតជាការរើសអើង ចំពោះការទទួលបានសម្ភារ/ឯកសារក្នុងទម្រង់ងាយស្រួលយល់សម្រាប់ជនពិការ"[៣]។

សន្ធិសញ្ញាម៉ារ៉ាកេសបានចូលជាធរមាននៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៦។ គិតត្រឹមដើមខែ មិថុនា ឆ្នាំ ២០១៧ មានប្រទេសចំនួន ២៨ បានចូលរួមក្នុងសន្ធិសញ្ញានេះ។[៤]

## បរិបទក្នុងប្រទេសកម្ពុជា

បើតាមការអង្កេតពាក់កណ្តាលជំរឿនប្រជាជន ឆ្នាំ ២០១៣ ដែលធ្វើឡើងដោយក្រសួងផែនការ [៥] ជនពិការក្នុងប្រទេសកម្ពុជាមាន ២,១ ភាគរយ ស្មើនឹងប្រមាណជា ៣០០០០០ នាក់ ដែលចំនួននេះមានការកើនឡើង ៥៧% បើធៀបជាមួយនឹងស្ថិតិឆ្នាំ ២០០៨។ ជនពិការគំហើញមានភាគរយខ្ពស់ជាងគេ ពោលគឺប្រមាណជា ៣៥% ក្នុងចំណោមចំនួនជនពិការសរុប ក្នុងប្រទេសកម្ពុជា។

កិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ដែលរាប់បញ្ចូលទាំងសិទ្ធិទទួលបានចំណេះដឹង សិទ្ធិទទួលបានការអប់រំ និងសិទ្ធិចូលរួមក្នុងសកម្មភាពវប្បធម៌ នឹងឆ្លើយតបចំពោះអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដូចជា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងអប់រំ យុវជន និងកីឡា និងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដែលស្ថាប័នទាំងនេះសុទ្ធតែផ្តោតការយកចិត្តទុកដាក់លើសិទ្ធិជនពិការក្រោមក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្ននេះ។ [៦] ការលើកស្ទួយសិទ្ធិជនពិការ ក៏មានសារៈសំខាន់ចំពោះការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា ស្របតាមគោលការណ៍ "មិនទុកអ្នកណាម្នាក់ចោល" និង "ខិតខំឲ្យទៅដល់អ្នកដែលនៅក្រោយគេមុនគេ" ផងដែរ។

ប្រទេសកម្ពុជាបានចុះហត្ថលេខាលើសន្ធិសញ្ញាម៉ារ៉ាកេស នៅពេលដែលអនុសញ្ញានេះបើកសម្រាប់ការចុះហត្ថលេខាកាលពីថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៣។ ប្រទេសកម្ពុជា គឺជាប្រទេសមួយ ក្នុងចំណោមសមាជិកអាស៊ាន តែពីរប្រទេសប៉ុណ្ណោះ ដែលបានចុះហត្ថលេខាលើសន្ធិសញ្ញានេះ ដែលនេះជាការបង្ហាញពីការប្តេជ្ញាចិត្តខ្ពស់របស់ប្រទេសកម្ពុជា ចំពោះការលើកកម្ពស់សិទ្ធិជនពិការ ទាំងនៅថ្នាក់ជាតិ ទាំងថ្នាក់សកល។ ប៉ុន្តែប្រទេសកម្ពុជាពុំទាន់បានផ្តល់សច្ចាប័នអនុសញ្ញានេះនៅឡើយ ដែលការផ្តល់សច្ចាប័ននេះជាជំហានចាំបាច់ ដើម្បីឲ្យប្រទេសនេះអាចចូលរួមជាមួយនឹងសន្ធិសញ្ញានេះជាផ្លូវការបាន។

ការផ្តល់សច្ចាប័ននេះតម្រូវឲ្យមានការផ្លាស់ប្តូរមួយចំនួន ក្នុងច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធរបស់ប្រទេសកម្ពុជា ដើម្បីឲ្យច្បាប់នេះអនុលោមទៅតាមលក្ខខណ្ឌតម្រូវ ដែលត្រូវបានដាក់ចេញក្នុងសន្ធិសញ្ញាម៉ារ៉ាកេស។ ឧទាហរណ៍ ច្បាប់នេះត្រូវបញ្ចូលបញ្ញត្តិមួយ ដើម្បីអនុញ្ញាតឲ្យមានការបង្កើត ឬការចែកចាយស្នាដៃបោះពុម្ពផ្សាយក្នុងទម្រង់ដែលងាយស្រួលសម្រាប់ជនពិការ។ លើសពីនេះ វិសាលភាពនៃបញ្ញត្តិមួយចំនួនរបស់ច្បាប់ដែលកំពុងចូលជាធរមានរួចទៅហើយនេះ ក៏ចាំបាច់ត្រូវពង្រីកវិសាលភាពបន្ថែមទៀតផងដែរ ម្បីផ្តល់លទ្ធភាពឲ្យស្ថាប័ន

៣ សូមមើលគេហទំព័រសន្ធិសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិជនពិការ https://www.un.org/development/desa/disabilities/convention-on-the-rights-of-persons-with-disabilities.html

៤ សូមមើលគេហទំព័រនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) ខាងលើ សម្រាប់បញ្ជីបច្ចុប្បន្នភាពនៃភាគីកិច្ចសន្យា

៥ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការនៃប្រទេសកម្ពុជា ( ២០១៣ ) របាយការណ៍ចុងក្រោយនៃការអង្កេតពាក់កណ្តាលជំរឿនប្រជាជនរបស់ប្រទេសកម្ពុជា ឆ្នាំ ២០១៣ http://www.stat.go.jp/info/meetings/cambodia/pdf/ci_fn02.pdf

## បរិបទក្នុងប្រទេសកម្ពុជា

ដែលបានទទួលការអនុញ្ញាត (ឧ. ស្ថាប័នដែលផ្តល់សេវាដល់ជនពិការដែលពិបាកអានឯកសារបោះពុម្ពដោយមិនរកប្រាក់ចំណេញ ដូចជា ស្ថាប័នរដ្ឋាភិបាល បណ្ណាល័យ អង្គការមិនមែនរដ្ឋាភិបាល ដូចជា សមាគមជនពិការភ្នែកកម្ពុជា ជាដើម) អាចនាំចូល និងនាំចេញឯកសារក្នុងទម្រង់ដែលងាយស្រួលយល់សម្រាប់ជនពិការបាន។

លើសពីនេះ ជាផ្នែកមួយនៃការអនុវត្តសន្ធិសញ្ញានេះ គួរមានការដាក់ឲ្យអនុវត្តនូវប្បញ្ញត្តិមួយ ដែលអនុញ្ញាតឲ្យមានការវៀងចេញពីវិធានការការពារបច្ចេកវិទ្យា ឬ "សោរឌីជីថល (digital lock)" ដែលបិទមុខងារមួយចំនួនសម្រាប់ ជួយដល់ជនពិការ ដូចជា សមត្ថភាពបម្លែងពីអត្ថបទទៅសម្លេងនិយាយ លើឧបករណ៍សម្រាប់អានសៀវភៅអេឡិចត្រូនិចជាដើម។

តាមរយៈការបង្កលក្ខណៈឲ្យមានការផ្តោះប្តូរឯកសារក្នុងទម្រង់ងាយស្រួលយល់សម្រាប់ជនពិការរវាងប្រទេសមួយ និងប្រទេសមួយ សន្ធិសញ្ញាម៉ារ៉ាកេសអាចផ្តល់ប្រយោជន៍ជាពិសេសដល់ប្រទេសតូចៗ ដែលមានឯកសារក្នុងទម្រង់ងាយស្រួលយល់សម្រាប់ជនពិការក្នុងមួយចំនួនមួយតិចតួច តួយ៉ាង ប្រទេសកម្ពុជា ជាដើម។ មានមនុស្សជាច្រើនដែលនឹងទទួលបានប្រយោជន៍បែបនេះ ដូចជា សិស្សពិការពិបាកអានឯកសារបោះពុម្ពដែលមានបំណងចង់រៀនភាសាអង់គ្លេស ឬភាសាបរទេសផ្សេងទៀត ក៏ដូចជាជនពិការដែលចាប់អារម្មណ៍ចំពោះការស្រាវជ្រាវថ្មីៗចុងក្រោយជាដើម។

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នអនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិជនពិការ (UNCRPD) ក្នុងឆ្នាំ 2012។ សន្ធិសញ្ញាម៉ារ៉ាកេស នឹងផ្តល់ឧបករណ៍ និងគុណប្រយោជន៍បន្ថែមផងដែរដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីបំពេញកាតព្វកិច្ចនេះជាច្រើន។

## ជំហានបន្ទាប់

ពិការភាពកើតឡើងចេញពី "អន្តរកម្មរវាងអ្នកដែលមានភាពខ្សោយ និងរបាំងអាកប្បកិរិយា និងបរិស្ថាន ដែលបន្ទុចបង្អាក់មិនឲ្យពួកគេអាចចូលរួមពេញលេញ ប្រកបដោយប្រសិទ្ធភាព ដោយស្មើភាពគ្នាជាមួយនឹងអ្នកដទៃទៀត" [៧] ពោលគឺមិនមែនកើតឡើង ដោយសារតែភាពខ្សោយតែឯងនោះទេ។

ការចូលរួម និងការអនុវត្តសន្ធិសញ្ញាម៉ារ៉ាកេសអាចផ្តល់ឲ្យប្រទេសកម្ពុជានូវលិខិតុបករណ៍គតិយុត្តិបន្ថែមមួយទៀត សម្រាប់ស្វែងរកការគាំទ្រ ការពារ និងលើកកម្ពស់សិទ្ធិជនពិការ។ សន្ធិសញ្ញានេះនឹងបង្កើតឱកាសពង្រឹងការឆ្លើយពហុវិស័យចំពោះជនពិការ និងការសហការជាមួយនឹងដៃគូថ្មីៗ ឧទាហរណ៍ ក្រសួងពាណិជ្ជកម្មដែលជាអ្នកដឹកនាំការអនុវត្តច្បាប់សិទ្ធិអ្នកនិពន្ធនៅក្នុងប្រទេសកម្ពុជា និងបណ្ណាល័យ ជាដើម។ សន្ធិសញ្ញានេះក៏នឹងជួយបើកទ្វារឲ្យកម្ពុជាអាចទទួលបានប្រយោជន៍ពីការសហការកាន់តែទូលំទូលាយបន្ថែមទៀតលើឆាកអន្តរជាតិ និងជំនួយថវិការ។

សម្រាប់ព័ត៌មានលំអិតបន្ថែមអំពីការវិភាគពីច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធរបស់ប្រទេសកម្ពុជា និងអនុសាសន៍នានា សូមមើលរបាយការណ៍ដែលរៀបចំរួមគ្នាដោយ UNDP និងសម្ព័ន្ធជនពិការពិភពលោក-អាស៊ីប៉ាស៊ីហ្វិច ក្រោមចំណងជើងថា "សិទ្ធិទទួលបានចំណេះដឹងរបស់យើង៖ ការពិនិត្យផ្នែកច្បាប់ សម្រាប់ការផ្តល់សច្ចាប័នលើសន្ធិសញ្ញាម៉ារ៉ាកេសស្តីពីជនពិការមិនអាចអានឯកសារបោះពុម្ពបាន នៅអាស៊ី និងប៉ាស៊ីហ្វិច - កំណែសម្រាប់ប្រទេសកម្ពុជា"ដែលមានជាភាសាខ្មែរ និងភាសាអង់គ្លេស លើគេហទំព័ររបស់ UNDP កម្ពុជា http://www.kh.undp.org/។ (របាយការណ៍ជាភាសាអង់គ្លេស ក៏មានជាទម្រង់ងាយស្រួលយល់សម្រាប់ជនពិការ ដូចជា ទម្រង់ជាអក្សរស្ទាបអេឡិចត្រូនិច DAISY និងសម្លេង (MP3) ផងដែរ )។[៨]

វេបសាយ ព័ត៌មានអេឡិចត្រូនិកសំរាប់បណ្ណាល័យ (EIFL) ផ្តល់នូវព័ត៌មាន មានសារៈប្រយោជន៍ អំពីសន្ធិសញ្ញាម៉ារ៉ាកេស: http://www.eifl.net/resources/implementation-marrakesh-treaty-eifl-faqs

ឯកសារសង្ខេបនេះមានជាភាសាអង់គ្លេស ភាសាខ្មែរ និង (ទម្រង់ដែលងាយស្រួលយល់សម្រាប់ជនពិការ)។

UNDP ផ្តល់ជំនួយបច្ចេកទេសផ្សេងៗ ដូចជា ការអភិវឌ្ឍសមត្ថភាព និងការសហការត្បូង-ត្បូង ជាដើម តាមរយៈការធ្វើការងារក្នុងភាពជាដៃគូជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា សមាគមជនពិការភ្នែកនៅកម្ពុជា សម្ព័ន្ធជនពិការពិភពលោក-អាស៊ីប៉ាស៊ីហ្វិច ទីភ្នាក់ងារសហប្រជាជាតិជាដៃគូ និងអ្នកពាក់ព័ន្ធផ្សេងទៀត។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងអ្នកស្រី ប៊ូ អមរា មន្ត្រីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) កម្ពុជា (amara.bou@undp.org) និង ប៊ុន ម៉ៅ នាយកប្រតិបត្តិសមាគមជនពិការភ្នែកនៅកម្ពុជា (boun.mao@online.com.kh)។

៦ រាជរដ្ឋាភិបាលកម្ពុជា (២០១២) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១២-២០១៨ http://cdc-crdb.gov.kh/cdc/documents/NSDP_2014-2018.pdf

៧ ដកស្រង់ចេញពីអារម្ភកថានៃសន្ធិសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិជនពិការ

៨ ទម្រង់ដែលងាយស្រួលយល់សម្រាប់ជនពិការអាចដោយទ្បូតបានពីគេហទំព័រនៃមជ្ឈមណ្ឌលប្រចាំតំបន់នៅទីក្រុងបាងកករបស់UNDP http://www.asia-pacific.undp.org/content/rbap/en/home/library/democratic_governance/hiv_aids/our-right-to-knowledge--legal-reviews-for-the-ratification-of-th.html